# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ១៣៤៩ គ.ជ.ប

## គោលការណ៍
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃកម្មវិធីផ្សព្វផ្សាយគោលនយោបាយ
## របស់គណបក្សនយោបាយ
## សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤

- យោងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

### ១. គោលបំណង

កម្មវិធីផ្សាយគោលនយោបាយរបស់គណបក្ស ត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដើម្បីឱ្យគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅតាមភូមិភាគ ហើយដែលបានទទួលស្គាល់ជាផ្លូវការដោយ គ.ជ.ប មានឱកាសធ្វើការឃោសនាផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនជូនដល់អ្នកបោះឆ្នោត សម្រាប់ចាក់ផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ (វិទ្យុ និងទូរទស្សន៍)។

### ២. ការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយ

គោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ សម្រាប់ផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ដែលរៀបចំឡើងដោយ គ.ជ.ប មានដូចខាងក្រោមៈ

២.១ កម្មវិធីឆ្លើយសំណួរទៅតាមប្រធានបទដែលកំណត់ដោយ គ.ជ.ប។

២.២ កម្មវិធីចាក់ផ្សាយស្ប៉ត (Spot) ដែលផលិតដោយសាមីគណបក្សនយោបាយ ដើម្បីផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ។

២.៣ ការបោះពុម្ពផ្សាយអត្ថបទឃោសនា អំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ឬប្រសាសន៍ដើមទាំងស្រុងរបស់បេក្ខជនឈរឈ្មោះបោះឆ្នោតលើព្រឹត្តិបត្រគោលនយោបាយគណបក្ស ដែលបោះពុម្ពផ្សាយដោយ គ.ជ.ប។



វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
St., Ratsaphea Tonle Basac, Khan Chamkar Mon, Phnom Penh, Cambodia
ទូរស័ព្ទ : 023 235 271
អ៊ីម៉ែល : info@nec.gov.kh

ការរៀបចំកម្មវិធីទាំងបី (៣) ខាងលើនេះ ត្រូវស្ថិតក្រោមការរៀបចំ ចាត់ចែង និងពិនិត្យដោយគណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយ សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ ដែលសម្រេចដោយ គ.ជ.ប។

## ៣. ការអនុវត្តគោលការណ៍

ការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយដែលចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ ត្រូវអនុវត្តតាមគោលការណ៍ស្មើភាព ដោយគណបក្សនយោបាយនីមួយៗទទួលបានម៉ោងផ្សាយតាមវិទ្យុជាតិកម្ពុជា និងទូរទស្សន៍ជាតិកម្ពុជាស្មើៗគ្នា ហើយរយៈពេលនេះនឹងត្រូវចាក់ផ្សាយឡើងវិញក្នុងថ្ងៃដដែល។

## ៤. ការទទួលខុសត្រូវរបស់គណបក្សនយោបាយ

គណបក្សនយោបាយ ត្រូវគោរពតាមការរៀបចំ និងចាត់ចែងដោយគណៈកម្មការសម្របសម្រួល ដែលរៀបចំការចាប់ឆ្នោតយកលំដាប់លេខរៀងមុនក្រោយសម្រាប់ការថត ទីកន្លែងអង្គុយម៉ោងផ្សាយ និងគោរពបទបញ្ជាសម្រាប់ការថតកម្មវិធី។

គណបក្សនយោបាយដែលចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយគោលនយោបាយ ត្រូវតែគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត និងគោរពតាមគោលការណ៍នេះ។

## ៥. ការទទួលខុសត្រូវខ្លឹមសារផ្សព្វផ្សាយ

គ.ជ.ប ជាអ្នកទទួលខុសត្រូវលើខ្លឹមសារផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ដែលរៀបចំឡើងដោយ គ.ជ.ប ហើយត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ២០២៣

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**